**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៨.សសរ..

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគម្រូតអាកាសយានដ្ឋានអន្តរជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ១១៧ សសរ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគម្រូតអាកាសយានដ្ឋានអន្តរជាតិ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សយ សុខាន់** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ប្រធាន |
| ២- | ឯកឧត្តមឧត្តមសេនីយ៍ទោ **ជា សំណាង** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ឡៅ ចន្ទ័ថារិទ្ធិ** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ឃុន សំបូរ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៥- | ឯកឧត្តម **ម៉ុន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិកប្រចាំការ |
| ៦- | ឯកឧត្តម **ទិត្យ ចន្ថា** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប | សមាជិកប្រចាំការ |
| ៧- | លោក **ហ៊ុន ឈឿន** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | សមាជិកប្រចាំការ |
| ៨- | លោកវរសេនីយ៍ឯក **ម៉ឹង មករា** | មេបញ្ជាការរងកងកម្លាំងពិសេសប្រឆាំងភេរវកម្ម | សមាជិក |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន ក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ